# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៧ . អនក្រ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការសម្របសម្រួលគម្រោងស្ថាបនាផ្លូវជាតិលេខ ១ (ក្បាលថ្នល់-អ្នកលឿង) និងគម្រោងស្ថាបនាស្ពានឆ្លងកាត់ទន្លេមេគង្គ (អ្នកលឿង)

៚៚៚

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ :** បង្កើតគណៈកម្មការសម្របសម្រួលគម្រោងស្ថាបនាផ្លូវជាតិលេខ ១ (ក្បាលថ្នល់-អ្នកលឿង) និងគម្រោងស្ថាបនាស្ពានឆ្លងកាត់ទន្លេមេគង្គ (អ្នកលឿង) ដែលមានសមាសភាព ដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | ត្រាំ អ៊ីវតឹក | រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២- ឯកឧត្តម | អ៊ុក ចាន់ | អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣- ឯកឧត្តម | ញាណ ឡេង | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤- ឯកឧត្តម | ទន្សី ទិស្សុត | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥- ឯកឧត្តម | នាយ សារ៉េត | អភិបាល ខេត្តព្រៃវែង | សមាជិក |
| ៦- លោក | ឃឹម បូរ | អភិបាលរងទី ១ ខេត្តកណ្តាល | សមាជិក |
| ៧- លោក | ឡេង សុជា | អគ្គលេខាធិការរង អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន | សមាជិក |

៨- លោក **តូច ចាន់កុសល** អគ្គនាយករងទី ១ អគ្គនាយកដ្ឋានសាធារណការ ក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

៩- លោក **លឹម ស៊ីដេនីន** នាយក នាយកដ្ឋានផ្លូវថ្នល់ អគ្គនាយកដ្ឋានសាធារណការ ក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

១០- លោក **ឃួយ ហៀង** ប្រធាននាយកដ្ឋានគមនាគមន៍ និងប្រៃសណីយ៍ ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១១- លោក **ចាន់ សុធី** ប្រធាននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១២- លោក **ខាវ ជុំ** ប្រធាននាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្រសួងបរិស្ថាន សមាជិក

១៣- បណ្ឌិត **ឌិប ទ័រង់ដេត** អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១៤- លោក **តី សុភាត់** នាយករង មជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេស សាធារណការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

១៥- លោក **មាស សឿន** ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកណ្តាល សមាជិក

**ប្រការ២ :** គណៈកម្មការមានភារកិច្ចសហការជាមួយស្ថានទូតជប៉ុន JICA និងក្រុមហ៊ុនជប៉ុន ក្នុងការដោះស្រាយលើផលប៉ះពាល់លំនៅដ្ឋាន ដីធ្លីប្រជាជន និងពិនិត្យដោះស្រាយបញ្ហាផ្សេងៗ សម្រាប់គម្រោងដែលអាចនឹងមាន ក្នុងពេលក្រុមហ៊ុនអនុវត្តគម្រោង ។

**ប្រការ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងប្រការមួយ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*ចម្លងជូន :*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចចែងក្នុងប្រការ ៣*
- *ឯកសារ-កាលប្បវត្តិ*